00600775

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/No: D314/1/12

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៥០)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 10 / 09 / 2010
ម៉ោង (Time/Heure): 11:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០

## សាធារណៈ:កោសល្ប

## សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
នួន ជា
អៀង សារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
នី ចាន់ឌី
Mahdev MOHAN
Lyma NGUYEN
គីម ម៉េងឃី

**សហមេធាវីការពារក្តីជនត្រូវចោទ**
អាង ឧត្តម
Michael G. KARVAVAS
សុន អរុណ
Michiel PESTMAN

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៥០ និង ៥១)

លេខ/No. D314/1/12

**សហចៅក្រមស៊ើបអង្កេត**

យូ ប៊ុនឡេង
Marcel LEMONDE

**ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង**

ម៉ុច សុវណ្ណារី
Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Françoise GAUTRY
Isabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN
ឡោ ជុនធី
ស៊ីន សុវ៉ន
សំ សុគង់
ហុង គីមសួន
គង់ ពិសី
គង់ ហេង
Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Partirck BAUDOUIN
ជេត វណ្ណលី
ពេជ អង្គ
Julien RIVET
Pascal AUBOIN

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (**"អ.វ.ត.ក"**) បានទទួល "បណ្តឹងសារណារបស់លោក អៀង សារី ទាក់ទងទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេតដែលធ្វើការពិចារណាឡើងវិញអំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី"[១] ("សារណាបន្ថែមរបស់ អៀង សារី") ដែលបាននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ និង "សារណាបណ្តឹងឧទ្ធរណ៍បន្ថែមប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសំណើរបស់ នួន ជា និង អៀង សារី សុំឱ្យកោះហៅសាក្សី"[២] ("សារណាបន្ថែមរបស់ នួន ជា") ដែលបានដាក់នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហមេធាវីការពារក្តី នួន ជា បានដាក់ "សំណើលើកទីប្រាំពីរស្នើសុំបើកកិច្ចស៊ើបអង្កេត"[៣] ("សំណើលើកទីប្រាំពីរ")។ សំណើនេះមានបំណងស្នើសុំឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ស្តាប់ចម្លើយ [redacted]"[៤]។

[១] បណ្តឹងសារណារបស់លោក អៀង សារី ទាក់ទងទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេតដែលធ្វើការពិចារណាឡើងវិញអំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ D314/1/10 ("សារណាបន្ថែមរបស់ អៀង សារី")។

[២] សារណាបណ្តឹងឧទ្ធរណ៍បន្ថែមប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសំណើរបស់ នួន ជា និង អៀង សារី សុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ D314/2/9 ("សារណាបន្ថែមរបស់ នួន ជា")។

[៣] សំណើលើកទីប្រាំពីរស្នើសុំបើកកិច្ចស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨ D122 ("សំណើលើកទីប្រាំពីរ")។

[៤] ដូចខាងលើ កថាខណ្ឌទី៦។

២. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ សហមេធាវីការពារក្តី នួន ជា បានដាក់ "សំណើលើកទីដប់ស្នើសុំបើកកិច្ចស៊ើបសួរ"[៥] ("សំណើលើកទីដប់") ដោយបានស្នើសុំឱ្យ ក.ស.ច.ស ស្តាប់ចម្លើយ[redacted] "អាចកំពុងកាន់កាប់ឯកសារ និងព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់តុលាការដែលកំពុងតែបន្តធ្វើ... ដែលព័ត៌មានខ្លះជាភស្តុតាងដោះបន្ទុកដែរ"[៦]។ សហមេធាវីការពារក្តីក៏បានស្នើសុំឱ្យ ក.ស.ច.ស "ទទួលយកឯកសារ និងព័ត៌មាន (រួមទាំងឯកសារទាំងឡាយ ដែលជាភស្តុតាងដោះបន្ទុកប្រកបដោយសក្តានុពល) ដែលឋិតនៅក្នុងការគ្រប់គ្រងរបស់[redacted] ទាក់ទងនឹងបញ្ហាទាំងឡាយដែលបានលើកឡើង"[៧]។ នៅក្នុងចំណុចចុងក្រោយ សហមេធាវីការពារក្តីបានស្នើសុំឱ្យ ក.ស.ច.ស "កំណត់អត្តសញ្ញាណអតីតមន្ត្រីកម្ពុជាប្រជាធិបតេយ្យទាំងអស់ ដែលកំពុងបំរើការងារនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដាក់ឈ្មោះ និងមុខតំណែងពីមុនៗ របស់ពួកគេទៅក្នុងសំណុំរឿង សម្រាប់ជាអំណះអំណាងនៅថ្ងៃខាងមុខនេះ"[៨]។

៣. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) បានឆ្លើយតបទៅនឹងសំណើលើកទីប្រាំពីរ និងសំណើលើកទីដប់ស្នើសុំបើកកិច្ចស៊ើបសួរ ដោយបានសម្រេចថា "[redacted]

---

[៥] សំណើលើកទីដប់ស្នើសុំបើកកិច្ចស៊ើបសួរ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ D136 ("សំណើលើកទីដប់")។

[៦] ដូចខាងលើ កថាខណ្ឌទី២០។

[៧] សំណើលើកទីដប់ កថាខណ្ឌទី២១(ក)។

[៨] ដូចខាងលើ កថាខណ្ឌទី២១(ឃ)។

[redacted]"[៩]។ ស.ច.ស.អ បានបំពេញកិច្ចជាឯកត្តោភាគីនៅពេលស្នើសុំឱ្យ [redacted] ចូលរួមនៅក្នុងការស្តាប់ចម្លើយ (តាមរយៈលិខិតចុះថ្ងៃទី១៥ និងថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩) និងនៅពេលចេញដីកាកោះហៅសាក្សីទាំងនេះ ដែលនៅមិនទាន់បានស្តាប់ចម្លើយ[១០]។ [redacted]។

៤. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ សហមេធាវីការពារក្តី នួន ជា បានដាក់ "សំណើសុំបំពេញកិច្ចស៊ើបសួរ" ដោយបានកំណត់ថាជាសំណើតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ("សំណើតាមវិធាន ៣៥")[១១]។ សហមេធាវីការពារក្តីបានលើកឡើងថា សំណើរបស់ខ្លួនបានធ្វើឡើងដោយឆ្លើយតបទៅនឹង "(i) ការចោទប្រកាន់ជាសាធារណៈទៅលើការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងកិច្ចការរបស់ អ.វ.ត.ក, (ii) ហេតុការណ៍នានាជុំវិញការអនុវត្តរបស់ ក.ស.ច.ស [redacted], (iii) ការកត់សម្គាល់ជាសាធារណៈរបស់លោក ហ៊ុន សែន ពាក់ព័ន្ធនឹងសាក្សីសំខាន់ៗរបស់ អ.វ.ត.ក, (iv) ជំហរដែលបានលើកឡើងជាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទិននឹងមន្ត្រីប្រាំមួយរូបដែលត្រូវបានកោះអញ្ជើញនោះ..."[១២]។

---

[៩] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ D301 ទំព័រទី១ ("ដីកាសម្រេចរបស់ ស.ច.ស")។

[១០] សូមមើល [redacted]។

[១១] សំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ D254 ("សំណើតាមវិធាន ៣៥")។

[១២] បណ្តឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌទី៦។

៥. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨ សហមេធាវីការពារក្ដី អៀង សារី បានចេញលិខិតមួយច្បាប់ ដោយធ្វើការស្នើសុំឱ្យ "ចេញដីកាកោះសារជាថ្មី ដើម្បីស្ដាប់ចម្លើយ [redacted]"[១៣]។ សំណើនេះក៏បានធ្វើការស្នើសុំ "ឱ្យចេញដីកាកោះឱ្យស្ដាប់ចម្លើយ [redacted] ផងដែរ[១៤]។

៦. នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ សហមេធាវីការពារក្ដី អៀង សារី បានដាក់ "សំណើសុំបំពេញកិច្ចស៊ើបសួរលើលើកទីដប់មួយ"[១៥] ("សំណើលើកទីដប់មួយ") ដោយ*ក្នុងនោះ*បានស្នើសុំឱ្យ ក.ស.ច.ស "កោះហៅ និងសាកសួរ [redacted] និងអតីតសមាជិកដទៃទៀតនៃរបបខ្មែរក្រហម និងសមាជិកបច្ចុប្បន្ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលកំពុងបម្រើការងារក្នុងស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការ..."[១៦]។ ស.ច.ស បានចេញដីកាសម្រេចឆ្លើយតបទៅនឹងសំណើត្រង់ចំណុចនេះ។

៧. នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ស.ច.ស.អ បានចេញដីកាសម្រេចជាឯកត្តោភាគី ដោយក្នុងនោះបានរៀបរាប់ពិស្ដារអំពីការបំពេញកិច្ចរបស់ខ្លួន ចំពោះសំណើលើកទីប្រាំពីរ និងសំណើលើកទីដប់ស្នើសុំបំពេញកិច្ចស៊ើបសួរ ដែលសហមេធាវីការពារក្ដី នួន ជា បានស្នើឡើង និងចំពោះលិខិតរបស់ក្រុមមេធាវីការពារក្ដី អៀង សារី។ [redacted]

---

[១៣] លិខិតក្រុមមេធាវីការពារក្ដី អៀង សារី ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨ D283 ("លិខិតកោះហៅសាក្សី")។

[១៤] លិខិតកោះហៅសាក្សី។

[១៥] សំណើសុំបំពេញកិច្ចស៊ើបសួរលើលើកទីដប់មួយ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ D284 ("សំណើលើកទីដប់មួយ")

[១៦] សំណើលើកទីដប់មួយ ទំព័រទី១០។

00600781



[redacted][18]។

៨. ចំពោះ[redacted] ស.ច.ស.អ បានកត់សម្គាល់ថា ខ្លួនបានបញ្ជូនដីកាកោះជូនទៅបុគ្គលទាំងនេះម្នាក់មួយច្បាប់ៗនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៩[19]។ "សាក្សីនីមួយៗបានទទួលដំណឹងអំពីដីកាកោះទាំងនេះ ដោយមិនអាចប្រកែកបាន មិនត្រឹមតែប៉ុណ្ណោះ ក្រឡាបញ្ជីក៏បានធ្វើរបាយការណ៍បញ្ជាក់អំពីករណីនេះផងដែរ"[20]។ ក្រោយពីមិនបានទទួលចម្លើយតបណាមួយពីបុគ្គលដែលត្រូវបានកោះហៅ ស.ច.ស.អ បានកត់សម្គាល់ថា "យើងមើលឃើញយ៉ាងច្បាស់ថា បុគ្គលទាំងនោះបានបដិសេធក្នុងការមកផ្តល់សក្ខីកម្ម"[21]។ ស.ច.ស.អ បដិសេធក្នុងការចាប់បង្ខំសាក្សី ដោយបានលើកឡើងថា "វិធានការចាប់បង្ខំអាចប៉ះទង្គិចទៅនឹងផលវិបាកជាក់ស្តែងនានាដែលក្នុងករណីទូទៅ បានពន្យារពេលដល់ការបិទកិច្ចស៊ើបសួរក្នុងថិរវេលាមួយដែលពុំអាចទទួលយកបាន ហើយមិនតែប៉ុណ្ណោះ បានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍នៃថិរវេលាសមស្របផងដែរ"[22]។ ស.ច.ស.អ បានសម្រេចថា យើងគួរទុក "លទ្ធភាពជូនអង្គជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ដើម្បីសិក្សាលើកាលានុវត្តនភាពក្នុងការប្រើប្រាស់នូវវិធានការចាប់បង្ខំនានា ក្នុងករណីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[23]។

---

[17] ដីកាសម្រេចរបស់ ស.ច.ស ទំព័រទី៣។

[18] ដូចខាងលើ។

[19] ដូចខាងលើ។

[20] ដូចខាងលើ។

[21] ដូចខាងលើ។

[22] ដីកាសម្រេចរបស់ ស.ច.ស ទំព័រទី៣។

[23] ដូចខាងលើ។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

៩. ក.ស.ច.ស បានចេញ "ដីកាសម្រេចលើសំណើរបស់ នួន ជា និង អៀង សារី សុំកោះហៅសាក្សី" ("ដីកាសម្រេចដែលត្រូវបានជំទាស់") ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០[២៤] ដើម្បីឆ្លើយតបទៅនឹងសំណើសុំបើកកិច្ចស៊ើបសួរដូចដែលបានលើកឡើងខាងលើ។ ដីកាសម្រេចដែលត្រូវបានជំទាស់នេះបានផ្តល់ដំណឹងដល់ភាគី [redacted]"[២៥]។ ស.ច.ស ជាតិ ("ស.ច.ស.ជ") បានប្រកាសថាសំណើសុំបំពេញកិច្ចស៊ើបសួរទាំងនេះត្រូវតែបដិសេធចោល ប៉ុន្តែ ស.ច.ស.អ បានបញ្ជាក់ថា "សំណើបំពេញកិច្ចស៊ើបសួរទាំងនេះត្រូវបានទទួលយកជាគោលការណ៍ ប៉ុន្តែមិនអាចបំពេញបាន ដូចមានបញ្ជាក់អំពីហេតុផលនៅក្នុងកំណត់សម្គាល់ដោយឡែក..."[២៦]។ សំណើដទៃទៀតត្រូវបានបដិសេធចោល។

១០. នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្តី នួន ជា បានដាក់ "សំណើសុំពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ នួន ជា និង អៀង សារី ស្នើសុំកោះអញ្ជើញសាក្សី"[២៧]។ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់ "ការជូនដំណឹងរបស់មេធាវីការពារក្តីអំពីភាសាសម្រាប់ដាក់ និងទទួលឯកសារ និងការស្នើសុំពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើរបស់ នួន ជា និង អៀង សារី ស្នើសុំកោះហៅសាក្សី"[២៨]។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួមនៅថ្ងៃទី២៤ ខែ

[២៤] ដីកាសម្រេចលើសំណើរបស់ នួន ជា និង អៀង សារី សុំកោះហៅសាក្សី ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ D314។

[២៥] ដូចខាងលើ ទំព័រទី៧។

[២៦] ដូចខាងលើ។

[២៧] សំណើសុំពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ នួន ជា និង អៀង សារី ស្នើសុំកោះអញ្ជើញសាក្សី ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ D314/2/1។

[២៨] ការជូនដំណឹងរបស់មេធាវីការពារក្តីស្តីអំពីភាសាសម្រាប់ដាក់ និងទទួលឯកសារ និងការស្នើសុំពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើរបស់ នួន ជា និង អៀង សារី ស្នើសុំកោះហៅសាក្សី ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០ D314/1/1។

00600783



កុម្ភៈ ឆ្នាំ២០១០ ដោយមិនបានបង្ហាញគោលជំហរណាមួយចំពោះសំណើទាំងនេះ[២៩]។ អង្គបុរេជំនុំជម្រះបានផ្តល់ការពន្យារពេលដល់ នួន ជា រហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០១០ និងដល់ អៀង សារី រហូតដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០[៣០]។

១១. នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ សហមេធាវីការពារក្តី អៀង សារី បានដាក់ "បណ្តឹងឧទ្ធរណ៍របស់ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសំណើរបស់ នួន ជា និង អៀង សារី សុំឱ្យកោះហៅសាក្សី ដែលត្រូវបាននិយាយយោងទៅដល់នៅក្នុងលិខិតរបស់គាត់ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ និងក្នុងកថាខណ្ឌ ២១(ឃ)នៃសំណើលើកទី១១ សុំឱ្យបំពេញកិច្ចស៊ើបសួរ" ("បណ្តឹងឧទ្ធរណ៍របស់ អៀង សារី")[៣១]។ បណ្តឹងឧទ្ធរណ៍នេះបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (i) ច្រានចោលការបដិសេធរបស់ ក.ស.ច.ស ទៅលើសំណើសុំឱ្យមានកិច្ចស៊ើបសួរលើកទីដប់មួយកន្លងមក ដោយសំណើនេះមានការពាក់ព័ន្ធនឹងការកោះហៅ និងសាកសួរ [redacted] និងអតីតសមាជិកដទៃទៀតក្នុងរបបខ្មែរក្រហម និងសមាជិកនានា ដែលបច្ចុប្បន្នកំពុងបម្រើការងារនៅក្នុងស្ថាប័នតុលាការ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា, និង (ii) ច្រានចោលការបដិសេធរបស់ ក.ស.ច.ស ទៅលើលិខិតស្នើឱ្យចេញដីកាកោះហៅ និងស្តាប់ចម្លើយឡើងវិញចំពោះ៖ [redacted]

---

[២៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងពាក្យសុំពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី និង នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើសុំកោះហៅសាក្សី ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ D314/1/2។

[៣០] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តីសុំពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ នួន ជា និងលើសំណើរបស់ អៀង សារី ស្នើសុំកោះអញ្ជើញសាក្សី ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១០ D314/2/3 និង សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តីសុំពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ ក.ស.ច.ស លើសំណើរបស់ នួន ជា និងលើសំណើរបស់ អៀង សារី ស្នើសុំកោះអញ្ជើញសាក្សី ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១០ D314/1/3។

[៣១] បណ្តឹងឧទ្ធរណ៍របស់ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសំណើរបស់ នួន ជា និង អៀង សារី សុំឱ្យកោះហៅសាក្សី ដែលត្រូវបាននិយាយយោងទៅដល់នៅក្នុងលិខិតរបស់គាត់ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ និងក្នុងកថាខណ្ឌ ២១(ឃ)នៃសំណើលើកទី១១ សុំឱ្យបំពេញកិច្ចស៊ើបសួរ ដាក់ប្តឹងនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ D314/1/4 ("បណ្តឹងឧទ្ធរណ៍របស់ អៀង សារី")។

[៣២] សហមេធាវីការពារក្តីរបស់ជនត្រូវចោទទាំងពីរ រួមទាំងសហព្រះរាជអាជ្ញាអន្តរជាតិ ... លើដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ [redacted]



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRÉLIMINAIRE

[redacted][៣៣]។

១២. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្ដី នួន ជា បានដាក់ “បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសំណើរបស់ជនត្រូវចោទ នួន ជា និងជនត្រូវចោទ អៀង សារី សុំឱ្យកោះហៅសាក្សី” (“បណ្ដឹងឧទ្ធរណ៍របស់ នួន ជា”) [៣៤]។ បណ្ដឹងឧទ្ធរណ៍នេះបានស្នើសុំឱ្យ (i) បដិសេធដីកាសម្រេច, និង (ii) ណែនាំ ក.ស.ច.ស ឱ្យបំពេញកិច្ចស៊ើបសួរឱ្យបានពេញលេញ តាមការស្នើសុំក្នុងសំណើទីប្រាំពីរ និងសំណើទីដប់ រួមទាំងសំណើតាមវិធាន៣៥[៣៥]។

១៣. នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្ដីសង្កេតទៅនឹងបណ្ដឹងឧទ្ធរណ៍ទាំងនេះ ហើយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ “ទទួលយកបណ្ដឹងឧទ្ធរណ៍នេះមួយចំណែក ហើយបញ្ជូនបញ្ហានេះត្រឡប់មកឱ្យសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីចាត់វិធានការដូចដែលមានចែងនៅក្នុងវិធាន ៦០(៣) ដើម្បីធានាប្រាកដចំពោះការបង្ហាញខ្លួនរបស់[redacted]ក្នុងសំណុំរឿងលេខ ០០២”[៣៦]។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ សហមេធាវីការពារក្ដី អៀង សារី បានដាក់ចម្លើយតប

---

ចៅក្រមស៊ើបអន្តរជាតិមិនបានកោះហៅ[redacted]

[៣៣] ដូចខាងលើ ទំព័រទី២៩។

[៣៤] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស.ស្ដីពីសំណើរបស់នួន ជា និងអៀង សារី សុំឱ្យកោះហៅសក្សី ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ឯកសារ D314/2/4 (“បណ្ដឹងឧទ្ធរណ៍របស់ នួន ជា”) ។

[៣៥] បណ្ដឹងឧទ្ធរណ៍របស់ នួន ជា កថាខណ្ឌទី៥១។

[៣៦] សេចក្ដីអង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជាស្ដីពីការកោះហៅសាក្សីបន្ថែម ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ D314/1/5 (“សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ”)។

ទៅនឹងសេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយធ្វើការលើកឡើងសារជាថ្មីចំពោះសំណើទាំងឡាយដែលមាននៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន[៣៧]។

១៤. នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញ "សាលដីកាសម្ងាត់លើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី" ("សាលដីកា")[៣៨]។ នៅពេលចេញសេចក្ដីសម្រេច អង្គបុរេជំនុំជម្រះ (i) បានរកឃើញថា បណ្ដឹងឧទ្ធរណ៍ទាំងនេះទទួលយកបាន, (ii) បង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាឡើងវិញលើសំណើទាំងនេះ ទៅតាមការបកស្រាយត្រឹមត្រូវលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង, (iii) តម្កល់សេចក្ដីសម្រេចរបស់សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ ដែលបានសម្រេចថា ការអនុវត្តការចាប់បង្ខំលើមន្ត្រីទាំងប្រាំមួយរូប ដែលបានកោះហៅនឹងនាំឱ្យមានការពន្យារពេលដល់ការបញ្ចប់កិច្ចស៊ើបសួរ និងយកសំអាងហេតុនៅក្នុងសាលដីកាមកជំនួសសំអាងហេតុរបស់សហ-ចៅក្រមស៊ើបអង្កេតអន្តរជាតិ, (iv) ទុកបញ្ហានេះសិន ដោយផ្ដល់រយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការដល់ ស.ច.ស ដើម្បីពិចារណាសំណើសុំឡើងវិញ និងផ្ដល់រយៈពេលពីរថ្ងៃនៃថ្ងៃធ្វើការដល់ដើមបណ្ដឹងឧទ្ធរណ៍ ដើម្បីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ និងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរ។

១៥. នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ស.ច.ស បានដាក់ "ដីកាឆ្លើយតបចំពោះសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើសុំកោះហៅសាក្សីរបស់ក្រុមមេធាវីការពារក្ដី នួន ជា

---

[៣៧] ចម្លើយតបរបស់ អៀង សារី ទៅនឹងសេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជាស្ដីពីការកោះហៅសាក្សីបន្ថែម ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ D314/1/7 ("សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ")។

[៣៨] សាលដីកាសម្ងាត់លើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ D314/1/8 និង D314/2/7 ("សាលដីកា")។

00600786



និង អៀង សារី" ("ដីកាសម្រេចពិចារណាសារជាថ្មីដែលត្រូវបានជំទាស់")[៣៩]។ នៅក្នុងដីកាសម្រេចពិចារណាសារជាថ្មីដែលត្រូវបានជំទាស់នេះ ស.ច.ស "បានធ្វើការពិនិត្យឡើងវិញលើសំណើសុំ ដោយពិចារណាលើការបកស្រាយរបស់អង្គបុរេជំនុំជម្រះចំពោះវិធាន ៣៥(១)(ឃ) នៃវិធានផ្ទៃក្នុង" ហើយបានតម្កល់សេចក្តីសម្រេចដំបូងរបស់ខ្លួន ដែលបានបដិសេធសំណើសុំ[៤០]។

១៦. នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ សហមេធាវីការពារក្តី នួន ជា បានដាក់សារណាបន្ថែមរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងដីកាសម្រេចពិចារណាសាជាថ្មី ដែលត្រូវបានជំទាស់។ សហមេធាវីការពារក្តីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (i) ស៊ើបអង្កេតថាតើការធ្វើអត្ថាធិប្បាយដោយឯកឧត្តម គង់ សំអុល ឯកឧត្តម ខៀវ កាញារិទ្ធ និងបុគ្គលដទៃទៀតនៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជានោះ អាចធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធភាព ឬឆន្ទៈរបស់សាក្សីទាំងឡាយ ដែល ស.ច.ស អន្តរជាតិ បានកោះអញ្ជើញឱ្យមកចូលរួមក្នុងការសម្ភាសន៍ស្តាប់យកចម្លើយដែរឬទេ, (ii) ដាក់ទណ្ឌកម្ម ឬ ចាត់វិធានការសមស្របចំពោះបុគ្គលណាមួយ ដែលត្រូវបានរកឃើញថាបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ, និង (iii) ចេញដីកាកោះឡើងវិញដើម្បីស្តាប់ចម្លើយសាក្សីដែលបានស្នើសុំ[៤១]។

១៧. នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ សហមេធាវីការពារក្តី នួន ជា បានដាក់សារណាបន្ថែមរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងដីកាសម្រេចសារជាថ្មីដែលត្រូវបានជំទាស់។ សហមេធាវី នួន ជា បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (i) បដិសេធដីកាសម្រេចចោល និង (ii) បង្គាប់ឱ្យ ក.ស.ច.ស បំពេញកិច្ចស៊ើបសួរទាំងអស់ ដូចបានស្នើសុំនៅក្នុងសំណើតាមវិធាន ៣៥[៤២]។ សំណើសុំបើកសវនាការជាសាធារណៈក៏បានធ្វើឡើងផងដែរ។

---

[៣៩] ដីកាឆ្លើយតបចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើសុំកោះហៅសាក្សីរបស់ក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ D314/3 ("ដីកាសម្រេចពិចារណាសារជាថ្មី ដែលត្រូវបានជំទាស់")។

[៤០] ដីកាសម្រេចពិចារណាសារជាថ្មី ដែលត្រូវបានជំទាស់ កថាខណ្ឌទី៥។

[៤១] សារណាបន្ថែមរបស់ អៀង សារី ទំព័រទី៥។

[៤២] សារណាបន្ថែមរបស់ នួន ជា ទំព័រទី៧។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

## II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១៨. អង្គបុរេជំនុំជម្រះមានអំណាចវិនិច្ឆ័យក្តីលើករណីនេះ អនុលោតាមវិធាន ៧៣(គ) នៃវិធានផ្ទៃក្នុង ដែលចែងថា៖

> បន្ថែមពីលើអំណាចវិនិច្ឆ័យសេចក្តីលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬ រវាងសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានតែអង្គបុរេជំនុំជម្រះប៉ុណ្ណោះដែលត្រូវមានសមត្ថកិច្ច ដើម្បីពិនិត្យលើ ៖
>
> [...]
>
> គ-បណ្តឹងឧទ្ធរណ៍ផ្សេងៗទៀត ដែលមានចែងនៅក្នុងវិធាន ១១(៥) និង (៦) វិធាន ៣៥(៦) វិធាន ៣៨(៣) និង វិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុងនេះ។

១៩. វិធាន ៣៥(៦) ចែងថា៖

> រាល់សេចក្តីសម្រេចដែលធ្វើឡើងក្រោមវិធាននេះ អាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឬ ប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល តាមករណីសមស្រប។ ចំពោះបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងចំពោះមុខអង្គបុរេជំនុំជម្រះ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវដាក់ពាក្យប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច ឬការជូនដំណឹងអំពីសេចក្តីសម្រេចនោះ តាមករណីសមស្រប។ ចំពោះបណ្តឹងសាទុក្ខដែលធ្វើឡើងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ម្ចាស់បណ្តឹងសាទុក្ខត្រូវធ្វើឡើងដោយអនុលោមទៅតាមនីតិវិធី និងរយៈពេលកំណត់ដូចមានចែងក្នុង វិធាន ១០៥ អនុវិធាន ២ និងវិធាន ១០៧ អនុវិធាន ១។

២០. ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះ *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* អាចបើកសវនាការ និងធ្វើការសម្រេចលើការចោទប្រកាន់ទាំងឡាយចំពោះការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ អនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង៖

> នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់ បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច...៖

២១. អង្គបុរេជំនុំជម្រះបានបញ្ជូនសំណើសុំនេះឱ្យទៅ ស.ច.ស ពិចារណាសារជាថ្មីនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ ដោយផ្តល់រយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការដល់ ស.ច.ស ដើម្បីពិចារណាសំណើនេះឡើងវិញ និងផ្តល់រយៈពេលពីរថ្ងៃនៃថ្ងៃធ្វើការដល់ភាគី ដើម្បីដាក់

សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរ។

២២. ដីកាសម្រេចពិចារណាសារជាថ្មីដែលត្រូវបានជំទាស់ត្រូវបានជូនដំណឹងដល់ភាគីជាភាសាបារាំង និងភាសាខ្មែរ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ និងជាភាសាអង់គ្លេសនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០។ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ សហមេធាវីការពារក្តី អៀង សារី បានជូនដំណឹងអំពីបំណងរបស់ខ្លួនក្នុងការដាក់បណ្តឹងឧទ្ធរណ៍ ហើយបានដាក់សារណាបន្ថែមនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ សហមេធាវីការពារក្តី នួន ជា បានជូនដំណឹងអំពីបំណងរបស់ខ្លួនក្នុងការដាក់បណ្តឹងឧទ្ធរណ៍ ហើយបានដាក់សារណាបន្ថែមនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១០[៤៣]។

២៣. ឯកសារទាំងអស់បានដាក់ និងជូនដំណឹងក្នុងរយៈពេលកំណត់ ដូចដែលបានកំណត់ដោយអង្គបុរេជំនុំជម្រះ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍ទាំងនេះអាចទទួលយកបាន។

## III. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

### ក. សាវតារ

២៤. នៅក្នុងសាលដីកា អង្គបុរេជំនុំជំនុំជម្រះ បានរកឃើញថា ស.ច.ស បានបកស្រាយវិធាន៣៥ នៃវិធានផ្ទៃក្នុង មិនបានត្រឹមត្រូវ ដែលនាំឱ្យមានកំហុសអង្គច្បាប់។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា "នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ ស.ច.ស ហាក់ដូចជាបានបកស្រាយវិធាន៣៥ នៃវិធានផ្ទៃក្នុង ថា ពាក្យសុំអាចធ្វើទៅបាន នៅពេលដែលមានការប៉ះពាល់លើសេចក្តីសម្រេច ឬកិច្ចរបស់ខ្លួនដោយហេតុមានការជ្រៀតជ្រែក។ ស.ច.ស យល់ឃើញថា នៅពេលដែលគេអាចសន្និដ្ឋានចេញភស្តុតាងថា ស.ច.ស បានខកខានក្នុងការអនុវត្តអំណាចរបស់ខ្លួន ឬក្នុងការបំពេញមុខងាររបស់ខ្លួនជាក់លាក់ ដោយសារមានការជ្រៀតជ្រែកតែប៉ុណ្ណោះ ទើបគេអាចយកវិធាន ៣៥ នៃវិធានផ្ទៃក្នុង មកអនុវត្ត

[៤៣] សាលដីកា ទំព័រទី២៩។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បាន"[៤៤]។ ជាលទ្ធផលនៃកំហុសនេះ អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យ ស.ច.ស សម្រេច "ថាតើគួរ ឬមិនគួរបើកការស៊ើបសួរ ដោយយោងតាមការបកស្រាយត្រឹមត្រូវលើ [វិធាន ៣៥ នៃវិធានផ្ទៃក្នុង] ទៅលើមតិយោបល់របស់បុគ្គលទាំងឡាយ ដែលមានឈ្មោះនៅក្នុងសំណើ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា ដែលមតិយោបល់ទាំងនេះអាចមានផលប៉ះពាល់ដល់លទ្ធភាព ឬឆន្ទៈរបស់សាក្សីដែលត្រូវបានកោះហៅដោយ ស.ច.ស.អ ឱ្យមកចូលរួមផ្តល់សក្ខីកម្ម"[៤៥]។

២៥. តាមការបង្គាប់ ស.ច.ស បានពិចារណាឡើងវិញទៅលើសំណើ ហើយបានដាក់ "ដីកាឆ្លើយតប ចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើសុំកោះហៅសាក្សីរបស់ក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី"។ ស.ច.ស បានអះអាងថា ខ្លួនបាន "ធ្វើការពិនិត្យឡើងវិញលើសំណើសុំ ដោយពិចារណាលើការបកស្រាយរបស់អង្គបុរេជំនុំជម្រះចំពោះវិធាន៣៥(១)(ឃ) នៃវិធានផ្ទៃក្នុង ជាពិសេសដើម្បីពិនិត្យអំពីអត្ថិភាពជាយថាហេតុនៃទំនាក់ទំនងរវាងសេចក្តីថ្លែងការណ៍របស់សមាជិកខ្លះ នៃរាជរដ្ឋាភិបាល និងការសម្រេចចិត្តរបស់សាក្សីក្នុងការមិនមកបង្ហាញខ្លួន"[៤៦]។ បន្ទាប់មក ស.ច.ស បានកត់សម្គាល់ថា "អ្វីដែលថ្មីដែលមិនមាននៅក្នុងដីកាសម្រេចកាលពីពេលមុន [redacted]"[៤៧]។ ស.ច.ស អះអាងថា "យោងតាមចំណុចទាំងអស់ខាងលើនេះ ការចោទប្រកាន់ទាំងអស់ដែលមានក្នុងសំណើសុំមិនមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការផ្តល់យុត្តិកម្មចំពោះការអនុវត្តបញ្ញត្តិនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង..."[៤៨]។ ស.ច.ស សន្និដ្ឋានថា ខ្លួននឹងមិនបើកកិច្ចស៊ើបសួរបន្ថែមនោះ

---

[៤៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣៥។

[៤៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤, យោង 'ដីកាកោះសាក្សី' [redacted]

[៤៦] ដីកាសម្រេចពិចារណាឡើងវិញដែលត្រូវបានជំទាស់ កថាខណ្ឌ ៥។

[៤៧] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥។

[៤៨] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ទេ ហើយនឹង "ទុកលទ្ធភាពបំពេញការងារនេះឱ្យអង្គបុរេជំនុំជម្រះ ដែលមានមូលដ្ឋានចាំបាច់គ្រប់គ្រាន់ក្នុងការសម្រេចសេចក្តី ជាអ្នកពិនិត្យក្នុងករណីចាំបាច់ ថាតើគួរឱ្យមានកិច្ចស៊ើបសួរបន្ថែម ឬមិនមានលើបញ្ហានេះ អនុលោមទៅតាមបញ្ញត្តិនៃវិធាន ៣៥(២) នៅក្នុងក្របខណ្ឌនៃបណ្តឹងឧទ្ធរណ៍ដែលខ្លួនទទួលបាន"[៤៩]។

## ខ. សារណា

២៦. ក្នុងចម្លើយតបរបស់ខ្លួនទៅកាន់ដីការសម្រេចពិចារណាឡើងវិញ ដែលត្រូវបានជំទាស់ សហមេធាវីការពារក្តីរបស់ អៀង សារី អះអាងថា ស.ច.ស មានកំហុសអង្គច្បាប់ និងបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ចៅក្រម។ សហមេធាវីការពារ លើកទឡ្ហីករណ៍ថា "ស.ច.ស មិនបានផ្តល់សំអាងហេតុថាតើហេតុអ្វីបានជាខ្លួន មិនយល់ឃើញថាគួរតែបើកកិច្ចស៊ើបអង្កេតទៅលើមតិយោបល់របស់ គង់ សំអុល, ខៀវ កាញារីទ្ធ និងអ្នកដទៃទៀតនៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា"[៥០]។ បន្ថែមលើនេះ ស.ច.ស មិនបានពិចារណាឡើងវិញចំពោះសំណើសុំ ទៅតាមការបកស្រាយត្រឹមត្រូវលើវិធាន៣៥ នៃវិធានផ្ទៃក្នុង ដូចបានបង្គាប់នោះទេ[៥១]។ សហមេធាវីការពារក្តី លើកទឡ្ហីករណ៍ថា ការខកខាននេះបណ្តាលឱ្យមានការរំលោភបំពានលើសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ ហើយនាំឱ្យមានកំហុសអង្គច្បាប់[៥២]។ សហមេធាវីការពារក្តី ក៏បានលើកទឡ្ហីករណ៍ផងដែរថា ស.ច.ស.អ បានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយយល់ឃើញថាសក្ខីកម្មរបស់បុគ្គលដែលបានរៀបរាប់ទាំងនោះ អាចនាំដល់ការបង្ហាញការពិត ប៉ុន្តែ ដោយមិនបានបើកកិច្ចស៊ើបអង្កេតទៅលើមូលហេតុដែលថា បុគ្គលទាំងនោះ មិនបានឆ្លើយតបទៅតាមដីកាកោះហៅរបស់ខ្លួន[៥៣]។

---

[៤៩] ដូចជើងទំព័រខាងលើ។

[៥០] សារណាបន្ថែមរបស់ អៀង សារី, កថាខណ្ឌ 4។

[៥១] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៦។

[៥២] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៦-៧។

[៥៣] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៨-១០។



អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

២៧. សហមេធាវីការពារក្តីរបស់ នួន ជា អះអាងថា សំអាងហេតុដែលមាននៅក្នុងដីកាសម្រេចពិចារណាឡើងវិញដែលត្រូវបានជំទាស់នោះ មានកំហុសអង្គច្បាប់ ហើយបាននាំឱ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់ចៅក្រម។ បន្ទាប់ពីរៀបរាប់កត្តាដែលអាចនាំឱ្យមានការអនុវត្តវិធាន៣៥ នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីអះអាងថា៖

> វាពិតជាមិនអាចទៅរួចទេ ការណ៍ដែល ក.ស.ច.ស ឆ្លើយតបទៅនឹងការចោទប្រកាន់ទាំងនេះដែលមានលក្ខណៈផ្សេងគ្នា លម្អិត មានភស្តុតាងបញ្ជាក់ត្រឹមត្រូវ និងការចោទប្រកាន់ដែលមិនជំទាស់បានដោយគ្រាន់តែអះអាងថាការចោទប្រកាន់ទាំងនេះ "មិនបានធានាដល់ការអនុវត្តបទបញ្ញត្តិវិធាន៣៥ នៃវិធានផ្ទៃក្នុង" ដោយពុំមានការផ្តល់យុត្តិកម្មបន្តិចសោះចំពោះការសន្និដ្ឋានរបស់ខ្លួននោះ។ សំខាន់ជាងនេះទៅទៀត នៅពេលដែលសហចៅក្រមស៊ើបអង្កេតយោងទៅរកការបកស្រាយវិធាន៣៥(១)(ឃ) [របស់អង្គបុរេជំនុំជម្រះ] ស.ច.ស ខកខានមិនបានបង្ហាញថាតើបទដ្ឋានដែលមានអំណាចបកស្រាយទៅអនុវត្តចំពោះអង្គហេតុដែលកំពុងមានបញ្ហានេះ ដោយរបៀបណានោះទេ។ បញ្ហាបែបនេះបង្កឱ្យមានកំហុសអង្គច្បាប់[៥៤]។

២៨. សហមេធាវីការពារក្តីរបស់ នួន ជា អះអាងបន្ថែមទៀតថា ការយោងរបស់ ស.ច.ស ទៅលើ "ការវិវត្តថ្មី" ដែលជាការកត់សម្គាល់របស់ [redacted] គឺមិនអាចយល់បាន។ សហមេធាវីការពារក្តីបន្តថា "ដីកាខកខានមិនបានបញ្ជាក់ថាតើ ក.ស.ច.ស យល់ឃើញថាការកត់សម្គាល់ទាំងនេះ *ប៉ះពាល់ដល់*ការចោទប្រកាន់នៅក្នុងសំណើលើវិធាន៣៥ ដែរឬទេ ជាជាង *គាំទ្រ* ជំហររបស់មេធាវីការពារក្តី ឬវា*មិនមានទំនាក់ទំនង*ជាមួយគ្នា"[៥៥]។ សហមេធាវីការពារក្តីលើកទឡ្ហីករណ៍ថា មាន"'មូលហេតុគ្រប់គ្រាន់ដើម្បីឱ្យជឿ' ថាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ 'អាច' កើតមានឡើង" ហេតុដូច្នេះ ស.ច.ស មានកំហុសដែលមិនបានបំពេញកិច្ចនេះ[៥៦]។ ជាចុងក្រោយ សហមេធាវីការពារក្តីរបស់ នួន ជា លើកទឡ្ហីករណ៍ថា ស.ច.ស បានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយបកស្រាយវិធាន៣៥ នៃវិធានផ្ទៃក្នុង ក្នុងន័យតូចចង្អៀតពេក[៥៧]។

[៥៤] សារណាបន្ថែមរបស់ នួន ជា កថាខណ្ឌ ១២។

[៥៥] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៣។

[៥៦] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៦។

[៥៧] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៧-១៩។

# គ. ច្បាប់ដែលយកមកអនុវត្ត

២៩. **វិធាន៣៥(១) ចែងថា៖**

អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម៖

[...]

ឃ. គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬផ្ដល់សំណូក ឬក៏ជ្រៀតជ្រែកលើសាក្សីណាម្នាក់ ឬលើអ្នកដែលអាចក្លាយជាសាក្សីដែលកំពុងផ្ដល់ បានផ្ដល់ ឬអាចផ្ដល់ភស្តុតាងដល់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

៣០. **វិធាន៣៥(២) នៃវិធានផ្ទៃក្នុង ចែងថា៖**

នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុងអនុវិធាន១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច៖

ក. ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។

ខ. ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឱ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី។ ឬ

គ. បញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច របស់ព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ។

៣១. **ស្រដៀងគ្នាទៅនឹងវិធាន៣៥ នៃវិធានផ្ទៃក្នុងនេះដែរ វិធានស្ដីពីនីតិវិធី និងការដាក់ភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") មានបទប្បញ្ញត្តិមួយ គឺវិធាន៧៧ ដែលចែងពីយន្តការសម្រាប់ថែរក្សាសុច្ចរិតភាពនៃដំណើរការរបស់តុលាការ នៅចំពោះមុខតុលាការអន្តរជាតិនោះ។ វិធាន៧៧ ចែងដូចខាងក្រោម៖**

(ក). នៅក្នុងការអនុវត្តអំណាចស្លាប័នរបស់ខ្លួន តុលាការអាចដាក់ទណ្ឌកម្មទៅលើជនទាំងឡាយណាដែលជ្រៀតជ្រែកដោយការដឹកឮ និងដោយចេតនា ក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយរួមទាំងបុគ្គលណាដែល

...

(iv) គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬផ្តល់សំណូក ឬក៏*រំខានដល់*សាក្សីណាម្នាក់ ដែលកំពុងផ្តល់ បានផ្តល់ ឬនឹងផ្តល់ភស្តុតាងនៅក្នុងកិច្ចនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ ឬទៅលើអ្នកដែលអាចក្លាយទៅជាសាក្សី។

(ខ) ការញុះញង់ ឬការព្យាយាមប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើទាំងឡាយណាដែលអាចផ្តន្ទាទោសបាន ដូចចែងក្នុងកថាខណ្ឌ (ក) អាចផ្តន្ទាទោសបានថាជាការប្រមាថតុលាការ ដែលនឹងទទួលបាននូវទណ្ឌកម្មដូចគ្នា[៥៨]។

៣២. ដោយមានភាពស្រដៀងគ្នាដែលអាចបង្ហាញបាន រវាងបទប្បញ្ញត្តិទាក់ទងនឹងការជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក និងនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង្គបុរេជំនុំជម្រះ បានយកយុទ្ធសាស្ត្រដែលអនុម័តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មកអនុវត្តទៅតាមការសមស្រប។

៣៣. អង្គបុរេជំនុំជម្រះបានកត់សម្គាល់រួចហើយ ដោយទទួលស្គាល់យុត្តិសាស្ត្ររបស់តុលាការ ICTY ទាក់ទងនឹង*ធាតុផ្សំសត្យានុម័ត*នៃការជេរប្រមាថតុលាការ ដែលអាចដាក់ទណ្ឌកម្មតាមវិធាន ៧៧ តាមការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងទី I នៅក្នុងសំណុំរឿង *រដ្ឋអាជ្ញា តទល់នឹង Haraqija និង Morina*[៥៩]។

> "ការគំរាមកំហែង" ត្រូវបានកំណត់និយមន័យថា ជាចេតនាបង្កឱ្យមានរបួស ឬការខូចខាតនានាទៅលើសាក្សីណាមួយ និង/ឬទ្រព្យសម្បត្តិរបស់សាក្សី ឬទៅលើបុគ្គលទីបីណាមួយ និង/ឬទ្រព្យសម្បត្តិរបស់គាត់ ដើម្បីជះឥទ្ធិពលទៅលើឆន្ទៈរបស់សាក្សីដែលទទួលរងនូវការគំរាមកំហែងនោះ។ "ការបំភិតបំភ័យ" រួមមានអំពើ ឬការធ្វើប្រហែសទាំងឡាយណា ដែលអាចបង្កឱ្យមានការគំរាមកំហែង ដោយផ្ទាល់ ដោយប្រយោល ឬដោយមានសក្តានុពល ទៅលើសាក្សីណាមួយ ដែលអំពើនេះ អាចរំខានដល់ ឬជ្រៀតជ្រែកទៅលើសក្ខីកម្មរបស់សាក្សី។ "ការរំខានដល់សាក្សីណាម្នាក់" គឺជាបទប្បញ្ញត្តិដែលមានន័យទូលំទូលាយមួយ ដែលគ្របដណ្តប់ទៅលើរាល់អំពើ ឬការធ្វើប្រហែសទាំងឡាយណា ក្រៅពីការគំរាម ការបំភិតបំភ័យ ការបង្ករបួសស្នាម ឬការផ្តល់

[៥៨] វិធាន ៧៧ នៃវិធានផ្ទៃក្នុង, តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, វិធាននីតិវិធី និងភស្តុតាង, ឯកសារ អ.ស.ប លេខ IT/32/Rev. 44 (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩) (គូសបញ្ជាក់បន្ថែម)។

[៥៩] សាលដីកា កថាខណ្ឌ ៤១។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

00600794



សំណួក ដែលអាច និងទំនងជាអាចធ្វើឱ្យសាក្សីផ្តល់សក្ខីកម្មមិនពេញលេញ និងមិនពិតប្រាកដ ឬដោយមធ្យោបាយផ្សេងទៀត អាចជ្រៀតជ្រែកទៅលើលក្ខណៈនៃភស្តុតាងរបស់សាក្សីនោះ។ ចុងបញ្ចប់ ដើម្បីបង្ហាញពីការទទួលខុសត្រូវរបស់ជនជាប់ចោទ វាមិនមានភាពសំខាន់ដើម្បីបង្ហាញថា តើសាក្សីពិតជាមានអារម្មណ៍ថាត្រូវបានគំរាមកំហែង ឬបំភិតបំភ័យ ឬត្រូវបានជំរុញមិនឱ្យធ្វើអ្វីមួយ ឬបានទទួលឥទ្ធិពលអ្វីមួយនោះទេ[៦០]។

៣៤. នៅក្នុងសំណុំរឿង *រដ្ឋអាជ្ញា តទល់នឹង Beqa Beqaj* អង្គជំនុំជម្រះសាលាដំបូងទី I នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានចេញសេចក្តីសង្កេតដ៏មានតម្លៃមួយចំនួន ទាក់ទងនឹងធាតុផ្សំសំខាន់ៗរបស់វិធាន៧៧។ អង្គជំនុំជម្រះនេះ បានកត់សម្គាល់ឃើញថា "គណៈកម្មាធិការអ្នកជំនាញទាក់ទងនឹងការបំភិតបំភ័យទៅលើសាក្សី និងសិទ្ធិការពារក្តីនៃក្រុមប្រឹក្សាអឺរ៉ុប បានកំណត់និយមន័យនៃពាក្យ 'ការបំភិតបំភ័យ' ថា ជា'ការគំរាមកំហែងដោយផ្ទាល់ ដោយប្រយោល ឬដោយមានសក្តានុពលទាំងឡាយណា ទៅលើសាក្សីដែលអំពើនេះអាចនាំឱ្យមានការរំខានដល់ករណីយកិច្ចរបស់សាក្សីនោះ ក្នុងការផ្តល់សក្ខីកម្មដែលមិនទទួលឥទ្ធិពលអ្វីទាំងអស់'"[៦១]។ អង្គជំនុំជម្រះនេះ ក៏បានចេញសេចក្តីសង្កេតមួយទៀត នៅក្នុងការសម្រេចរបស់ខ្លួន ដែលមានខ្លឹមសារដូចខាងក្រោម៖

> វាក្យស័ព្ទ 'ឬរំខានដល់សាក្សី ឬអ្នកដែលអាចក្លាយទៅជាសក្សីណាមួយ' គឺជាការបញ្ជាក់បង្ហាញថាវិធាន៧៧ ចែងមិនពេញលេញ អំពីទម្រង់នៃអំពើដែលជាការប្រមាថដល់តុលាការ។ ដោយពិចារណាទៅលើ*ធាតុផ្សំសត្យានុម័ត*ដែលមាននៅក្នុងវិធាន៧៧(ក) អង្គជំនុំជម្រះយល់ឃើញថា ពាក្យ 'ឬរំខានដល់សាក្សី' រួមបញ្ចូលអំពើទាំងឡាយណាដែលបានប្រព្រឹត្តឡើងក្នុងគោលបំណងរំខានដល់កិច្ចការរដ្ឋបាលរបស់តុលាការ ដោយជំរុញមិនឱ្យសាក្សីណាមួយ ឬអ្នកដែលអាចក្លាយទៅជាសាក្សី ផ្តល់ភស្តុតាងពេញលេញ និងពិតប្រាកដ ឬដោយមធ្យោបាយផ្សេងទៀត ជះឥទ្ធិពលទៅលើលក្ខណៈនៃភស្តុតាងរបស់សាក្សី ឬរបស់អ្នកដែលអាចក្លាយទៅជាសាក្សី។ មិនមានការបង្ហាញណាមួយដែលតម្រូវឱ្យមានការបង្ហាញភស្តុតាងថា អំពើដែលបានប្រព្រឹត្តឡើងក្នុងគោល

---

[៦០] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Beqa Beqaj* និង *Morina* IT-04-84-R77 "សាលក្រមលើការចោទប្រកាន់អំពីការជេរប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌ ១៨។

[៦១] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Beqa Beqaj* IT-03-66-T-R77 "សាលក្រមលើការ[illegible]ជេរប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥, កថាខណ្ឌ [illegible]។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

បំណងជះឥទ្ធិពលទៅលើលក្ខណៈនៃភស្តុតាងរបស់សាក្សី បានបង្កើតបានទៅជាលទ្ធផលណាមួយនោះទេ[៦២]។

៣៥. *ធាតុផ្សំអត្តនោម័ត*នៃវិធាន៣៥ នៃវិធានផ្ទៃក្នុង តម្រូវថា អ្នកជ្រៀតជ្រែកត្រូវតែបានប្រព្រឹត្តអំពើនោះ*ដោយមានការដឹងឮ និងដោយចេតនា*។ អង្គជំនុំជម្រះនេះ ធ្លាប់សង្កេតរួចហើយថា "នៅពេលបង្ហាញពី *ធាតុផ្សំអត្តនោម័ត* គេត្រូវបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តអំពើដោយចេតនាពិតប្រាកដ ហើយដឹងថា អំពើរបស់ខ្លួនទំនងនឹងរារាំង ឬជ្រៀតជ្រែកដល់សាក្សី ឬអ្នកដែលអាចក្លាយទៅជាសាក្សី"[៦៣]។

៣៦. បទដ្ឋានក្នុងការបង្ហាញភស្តុតាង មានចំនួនបីផ្សេងៗគ្នា ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ នៅពេលពិចារណាអំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង។ បទដ្ឋានទាំងនេះគឺ (i) មូលហេតុអាចឱ្យជឿបាន, (ii) មូលដ្ឋានគ្រប់គ្រាន់ និង (iii) ឱ្យហួសពីវិមតិសង្ស័យ។ បទដ្ឋាននៃការបង្ហាញថាមាន *មូលហេតុអាចឱ្យជឿបាន* ត្រូវបានចែងនៅក្នុងវិធាន៣៥(២) នៃវិធានផ្ទៃក្នុង ដែលផ្តល់នូវចំណាត់ការចំនួនបី នៅពេលដែល "សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះមាន*មូលហេតុអាចឱ្យជឿបាន* ថាបុគ្គលណាមួយអាចបានប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើទាំងឡាយ" ដែលត្រូវរៀបរាប់នៅក្នុងវិធាន៣៥(១) នៃវិធានផ្ទៃក្នុង[៦៤]។ បទដ្ឋានដែលតម្រូវឱ្យមាន*មូលដ្ឋានគ្រប់គ្រាន់* ត្រូវតែបំពេញ ដើម្បីឱ្យមានការបើកកិច្ចដំណើរការនីតិវិធី ចាត់ការបញ្ហានោះភ្លាមៗ ឬបញ្ជូនបញ្ហានោះឱ្យទៅស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសកម្ពុជា ឬរបស់អង្គការសហប្រជាជាតិ។ បទដ្ឋាននៃការបង្ហាញ

---

[៦២] ដូចខាងលើ កថាខណ្ឌទី២១។

[៦៣] សាលដីកា កថាខណ្ឌ ៤១។

[៦៤] វិធាន ៣៥(២) នៃវិធានផ្ទៃក្នុងចែងថា នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់ បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច ក-ចាត់ការជាមួយបញ្ហានេះជាបន្ទាន់ ខ-ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឱ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ឬ គ-បញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ឬ អង្គការសហប្រជាជាតិ។

ភស្តុតាង*ឱ្យហួសពីវិមតិសង្ស័យ* ត្រូវតែបំពេញ មុននឹងអនុវត្តនូវការដាក់ទណ្ឌកម្មនានា ទៅលើបុគ្គលដែលបានរំលោភបំពានលើវិធាន៣៥(១) នៃវិធានផ្ទៃក្នុង។

៣៧. វិធានផ្ទៃក្នុងមិនបានកំណត់និយមន័យនៃបទដ្ឋាននៃការបង្ហាញភស្តុតាងទាំងបីនេះទេ ប៉ុន្តែ គេអាចវែកញែកបទដ្ឋានទាំងនេះឱ្យដាច់ពីគ្នាបាន ទៅតាមដំណាក់កាលនៃកិច្ចស៊ើបសួរ។ បទដ្ឋានដែលតម្រូវឱ្យមាន*មូលហេតុអាចឱ្យជឿបាន* គឺជាបទដ្ឋានដែលមានលក្ខណៈ ស្រាលបំផុត ហើយនឹងអាចនាំឱ្យមានការស៊ើបសួរពីសហចៅក្រមស៊ើបអង្កេត ឬអង្គ ជំនុំជម្រះណាមួយ។ លក្ខណៈទូលំទូលាយនៃបទដ្ឋានមួយនេះ ត្រូវបានបញ្ជាក់ដោយ ការប្រើប្រាស់ពាក្យ *អាច* នៅក្នុងវិធាន៣៥(២) នៃវិធានផ្ទៃក្នុង។ ការរកឃើញថា មាន ហេតុផលជឿ មិនតម្រូវឱ្យមានសេចក្តីសម្រេចណាមួយទៅលើអង្គសេចក្តីនៃការចោទ ប្រកាន់ ឬភាពសង្ស័យនៃការជ្រៀតជ្រែតនោះទេ។ ប៉ុន្តែ ចំពោះការរកឃើញថា បទដ្ឋាននៃការមានហេតុផលជឿបានបំពេញ ការរកឃើញតម្រូវឱ្យ ស.ច.ស ឬ អង្គជំនុំ ជម្រះសន្និដ្ឋានថា មានមូលដ្ឋានជាក់លាក់ ឬ*មូលហេតុ* ដែលជាមូលដ្ឋាននៃ *ជំនឿ* របស់ ខ្លួន។ មូលដ្ឋានជាក់លាក់ ឬ*មូលហេតុ* ត្រូវតែបង្ហាញឱ្យឃើញ ដោយផ្អែកលើការពិនិត្យ លើការចោទប្រកាន់ ឬ ការសង្ស័យ ដែលការពិនិត្យនេះ អាចមានលក្ខណៈជាអត្តនោម័ត។

៣៨. បទដ្ឋាននៃការបង្ហាញភស្តុតាងទី២ ពោលគឺ*មូលដ្ឋានគ្រប់គ្រាន់* ត្រូវបានពណ៌នាយ៉ាងត្រឹម ត្រូវបំផុតដោយអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ អតីតប្រទេសយូហ្គោស្លាវី។ អង្គជំនុំជម្រះនេះកត់សម្គាល់ថា បទដ្ឋានដែលទាមទារឱ្យមាន *មូលដ្ឋានគ្រប់គ្រាន់* "តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូង គ្រាន់តែបង្ហាញថាតើភស្តុតាង មាននៅចំពោះមុខខ្លួន បង្ហាញជា*បឋម* ថាមានករណីប្រមាថតុលាការដែរឬទេ ហើយមិន តម្រូវឱ្យធ្វើការសម្រេចចុងក្រោយថា តើមានការប្រមាថដែរឬទេ នោះឡើយ"[៦៥]។ អង្គ បុរេជំនុំជម្រះធ្លាប់បានកត់សម្គាល់ ដោយមានការឯកភាព កន្លងរួចមកហើយ ពីការប្រៀប

[៦៥] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Šešelj,* IT-03-67-AR77/2 "សាលដីកាលើបណ្តឹងសារទុក្ខរបស់ស្ថាប[illegible] ប្រឆាំងចំពោះ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨ អង្គជំនុំជម្រះ[illegible] កំពូល ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨, កថាខណ្ឌ ១៦។

ធៀបរវាងបទដ្ឋានដែលតម្រូវឱ្យមាន *មូលដ្ឋានគ្រប់គ្រាន់* និងបទដ្ឋានដែលតម្រូវឱ្យមានភស្តុតាង *បឋម*[៦៦]។

៣៩. បទដ្ឋាននៃការបង្ហាញភស្តុតាង *ឱ្យហួសពីវិមតិសង្ស័យ* ត្រូវតែបំពេញ ដើម្បីអាចដាក់ទណ្ឌកម្មទៅលើបុគ្គលណាមួយដែលរំលោភបំពានលើវិធាន៣៥(១) នៃវិធានផ្ទៃក្នុង។ បទដ្ឋានមួយនេះគឺជាបទដ្ឋានដែលត្រូវបានទទួលយកជាសកល ជាបទដ្ឋាននៃការបង្ហាញភស្តុតាងនៅក្នុងរឿងព្រហ្មទណ្ឌ។

## ឃ. អង្គហេតុ

៤០. ខាងក្រោមនេះគឺជាការរៀបរាប់លើអង្គហេតុសំខាន់ៗ ដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ៖

ក. នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ស.ច.ស.អ បានកោះហៅ [redacted] ("មន្ត្រីទាំងប្រាំមួយរូប") ដើម្បីសាកសួរចម្លើយ[៦៧]។ ស.ច.ស.អ បានចេញដីកាកោះទាំងនេះ ក្រោយពីទទួលបានសំណើលើកទី ៧ និងសំណើលើកទី ១០ របស់លោក នួន ជា សុំបំពេញកិច្ចស៊ើបសួរ ហើយដោយផ្អែកលើការសម្រេចថា សក្ខីកម្មរបស់មន្ត្រីទាំងនេះនឹងអាចជួយដល់កិច្ចដំណើរការស្វែងរកការពិត។

ខ. ដីកាកោះទាំងនេះបានចេញផ្សាយនៅក្នុងសារព័ត៌មាន[៦៨]។ សារព័ត៌មានក៏បានរាយការណ៍ថា មន្ត្រីទាំង ៦ រូប នេះកំពុងគិតគូរឆ្លើយតបទៅនឹងដីកាកោះទាំងនេះ។

---

[៦៦] [redacted]។

[៦៧] 'ដីកាកោះសាក្សី' [redacted]។

[៦៨] សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ មានចំណងជើងថា៖ 'Hun Sen Critizes Summoning of CPP Officials' ចេញផ្សាយថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩។ សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ មានចំណងជើងថា៖ 'Govt. testimony could

គ. នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១០ កាសែតភ្នំពេញប៉ុស្តិ៍បានចេញផ្សាយអត្ថបទមួយ ដែលមានចំណងជើងថា "សក្ខីកម្មរបស់រដ្ឋាភិបាលអាចលម្អៀងចំពោះសាលាក្តីខ្មែរក្រហម៖ នាយករដ្ឋមន្ត្រី"។ អត្ថបទនេះរួមបញ្ចូលនូវខ្លឹមសារដូចខាងក្រោម៖

> មួយថ្ងៃមុននេះ អ្នកនាំពាក្យរដ្ឋាភិបាល ខៀវ កាញារីទ្ធ បាននិយាយថា បើទោះជាមន្ត្រីទាំងនេះ អាចចូលខ្លួនទៅតុលាការដោយខ្លួនឯងក៏ដោយ តែជំហររបស់រដ្ឋាភិបាលគឺគាត់មិនគួរផ្តល់សក្ខីកម្មនោះទេ។ លោកបាននិយាយថា បុគ្គលិកបរទេសអាចវេចសម្លៀកបំពាក់ ហើយត្រឡប់ទៅផ្ទះវិញ" ប្រសិនបើមិនពេញចិត្តនឹងសេចក្តីសម្រេចនេះ[៦៩]។

ឃ. រាជរដ្ឋាភិបាលកម្ពុជា មិនបានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីកែតម្រូវ ឬបដិសេធចោលយោបល់របស់ ខៀវ កាញារីទ្ធឡើយ។

ង. នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ស.ច.ស.អ បានសន្និដ្ឋានទាក់ទងនឹងមន្ត្រីទាំង ៦ នាក់នេះ ដោយផ្អែកលើព័ត៌មានដែលខ្លួនមានថា "បុគ្គលដែលពាក់ព័ន្ធបានបដិសេធមិនចូលរួមមកផ្តល់សក្ខីកម្ម"[៧០]។ តាមអង្គបុរេជំនុំជម្រះបានដឹង មកទល់ពេលនេះ មន្ត្រីទាំង ៦ រូបនេះ បានខកខានមិនបានមកផ្តល់សក្ខីកម្មតាមសំណើសុំនោះទេ។

## ខ. សេចក្តីសម្រេច

**៤១. អង្គបុរេជំនុំជម្រះខកខានមិនអាចរកសេចក្តីសម្រេចដែលមានសម្លេងច្រើនលើសលប់បានថាតើ ស.ច.ស មានការភ័ន្តច្រឡំដែរឬអត់ នៅពេលសន្និដ្ឋានថា ភស្តុតាងដែលបានដាក់នៅចំពោះមុខខ្លួននាំឱ្យខ្លួនមានហេតុផលដែលគួរឱ្យជឿថា ការជ្រៀតជ្រែកមួយ អនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង អាចទំនងកើតឡើងដែរឬដែរ។**

---

bias KRT: PM' ចេញផ្សាយថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩។ សារព័ត៌មាន Cambodia Daily មានចំណងជើងថា៖ 'ECCC Judge Calls Officials to Testify' ចេញផ្សាយថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩។ សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ មានចំណងជើងថា៖ 'KR Tribunal Summons Top Officials' ចេញផ្សាយថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩។

[៦៩] សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ មានចំណងជើងថា៖ 'Govt testimony could bias KRT: PM' ចេញផ្សាយថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩។

[៧០] ដីកាសម្រេច ទំព័រ៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

00600799



## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច៖

១. **ទទួលយក**បណ្តឹងឧទ្ធរណ៍។

២. **បដិសេធ**បណ្តឹងឧទ្ធរណ៍ចោល។ និង

៣. **បដិសេធ**ពាក្យសុំនេះចោល។

**ភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០**

**អង្គបុរេជំនុំជម្រះ**

Rowan DOWNING **ន័យ ថុល** Catherine MARCHI-UHEL **ហួត វុទ្ធី** **ប្រាក់ គីមសាន**

**មតិយោបល់របស់ចៅក្រម** CATHERINE MARCHI-UHEL **និង** ROWAN DOWNING

១. សហមេធាវីការពារក្តី នួន ជា និង អៀង សារី ពិតជាត្រឹមត្រូវនៅពេលលើកឡើងថា សំអាងហេតុនៅក្នុងនៅក្នុងដីកាសម្រេចពិចារណាឡើងវិញដែលត្រូវបានជំទាស់ បាន បង្កើតជាការភ័ន្តច្រឡំលើអង្គច្បាប់ និងការរំលោភបំពានលើឆន្ទានុសិទ្ធិ។ នៅក្នុងសេចក្តី សម្រេចចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានបង្គាប់ ស.ច.ស ឱ្យ "ពិចារណាឡើងវិញលើសំណើទាំងនេះ ទៅតាមការបកស្រាយត្រឹមត្រូវលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង"[៧១]។ ស.ច.ស បានធ្វើការឆ្លើយតបដោយគ្រាន់តែលើកឡើងថា ខ្លួន"បាន ធ្វើការពិនិត្យឡើងវិញលើសំណើសុំ ដោយពិចារណាលើការបកស្រាយរបស់អង្គបុរេជំនុំ ជម្រះចំពោះវិធាន ៣៥(១)(ឃ) នៃវិធានផ្ទៃក្នុង" ហើយបាន "ពិចារណាថា ការចោទ ប្រកាន់ទាំងអស់ ដែលមានក្នុងសំណើសុំមិនមានមូលដ្ឋានគ្រប់គ្រាន់ក្នុង...ការអនុវត្តបញ្ញត្តិ នៃវិធាន៣៥ នៃវិធានផ្ទៃក្នុង នៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះឡើយ"[៧២]។ ស.ច.ស មិនបានផ្តល់ការពន្យល់ ឬមូលដ្ឋាន ដែលខ្លួនយកមកធ្វើការសម្រេច។ ការអះអាងដោយ គ្មានមូលដ្ឋានទាំងនេះ មិនអាចឱ្យយើងជឿថា ស.ច.ស ពិតជាបានពិចារណាឡើងវិញ លើសំណើទាំងនេះ តាមការបង្គាប់ឡើយ។

២. នៅក្នុងការសម្រេចតម្កល់ការបដិសេធលើសំណើទាំងនេះ ស.ច.ស កត់សម្គាល់ថា

> អ្វីដែលថ្មីដែលមិនមាននៅក្នុងដីកាសម្រេចកាលពីលើកមុន គឺការលើកឡើង [redacted][៧៣]។

៣. យោបល់នេះមិនទាក់ទិនអង្គហេតុសំខាន់ចំពោះការចោទប្រកាន់លើលទ្ធភាពថា អាចមាន ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយរាជរដ្ឋាភិបាលនៃព្រះរាជ-

[៧១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ទំព័រ២៨។

[៧២] ដីកាសម្រេចពិចារណាឡើងវិញដែលត្រូវបានជំទាស់ កថាខណ្ឌ៤ និង ៦។

[៧៣] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥។

ណាចក្រកម្ពុជាឡើយ។ យោបល់នេះគ្មានតម្លៃជាភស្តុតាងនៅក្នុងការវាយតម្លៃលើខ្លឹមសារនៃការចោទប្រកាន់ចម្បងៗឡើយ។

៤. បន្ថែមពីនេះ ស.ច.ស សន្និដ្ឋាននៅក្នុងដីកាសម្រេចពិចារណាសារជាថ្មីដែលត្រូវបានជំទាស់ថា ស.ច.ស "ទុកលទ្ធភាពបំពេញការងារនេះឱ្យអង្គបុរេជំនុំជម្រះ ដែលមានមូលដ្ឋានចាំបាច់គ្រប់គ្រាន់ក្នុងការសម្រេចសេចក្តី ជាអ្នកពិនិត្យក្នុងករណីចាំបាច់ ថាគួរឱ្យមានកិច្ចស៊ើបសួរបន្ថែម ឬមិនមានលើបញ្ហានេះ អនុលោមតាមទៅតាមបញ្ញត្តិនៃវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង..."[៧៤]។ ការបង្វែរការទទួលខុសត្រូវបែបនេះ មិនមានលក្ខណៈគួរឱ្យពេញចិត្តឡើយ។ វិធាន ៣៥(៦) នៃវិធានផ្ទៃក្នុងផ្តល់យុត្តាធិការដល់អង្គបុរេជំនុំជម្រះក្នុងការស្តាប់ និងសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ស.ច.ស ចំពោះការចោទប្រកាន់ថាមានការរំលោភបំពានលើវិធាន ៣៥(១)នៃវិធានផ្ទៃក្នុង។ បន្ថែមពីនេះ វិធាន៣៥(២) នៃវិធានផ្ទៃក្នុងផ្តល់អំណាចដល់អង្គបុរេជំនុំជម្រះឱ្យចាត់វិធានការដោយឯករាជ្យ ប្រសិនបើខ្លួនជឿថា មាន"ហេតុផលគួរឱ្យជឿជាក់ថា" បុគ្គលណាម្នាក់ "អាច" ប្រព្រឹត្តអំពើជ្រៀតជ្រែកណាមួយ។ ប៉ុន្តែ វិធានផ្ទៃក្នុងមិនបានផ្តល់មូលដ្ឋាន ដែល ស.ច.ស អាចសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ឬពាក្យសុំ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ និងអាចរុញ ឬ បង្វែរបញ្ហានេះទៅឱ្យអង្គបុរេជំនុំជម្រះឡើយ។ យើងគួរកត់សម្គាល់ផងដែរថា ការសម្រេចអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង មិនមានការជាប់ពាក់ព័ន្ធនឹងដំណាក់កាលនីតិវិធីនេះឡើយ ទោះក្នុងមធ្យោបាយណាក៏ដោយ ដូចដែល ស.ច.ស បានសន្និដ្ឋានដោយលើកឡើងថា បទប្បញ្ញត្តិនេះមិនមានមូលដ្ឋានអនុវត្ត "នៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះឡើយ"[៧៥]។

៥. ដោយសារ ស.ច.ស ខកខានមិនបានបំពេញម្តងហើយម្តងទៀត យើងយល់ឃើញថា ដោយពិចារណាលើលក្ខណៈធ្ងន់ធ្ងរនៃការចោទប្រកាន់អំពីការជ្រៀតជ្រែក អង្គបុរេជំនុំជម្រះត្រូវតែធ្វើអន្តរាគមន៍។ ដូចដែលបានធ្វើការសង្កេតមុនៗ ស.ច.ស ត្រូវបំពេញកិច្ចអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង នៅពេលខ្លួនមាន "ហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តអំពើណាមួយ ដូចចែងនៅក្នុងអនុវិធាន ១ ខាងលើ"។

---

[៧៤] ដីកាសម្រេចពិចារណាឡើងវិញដែលត្រូវបានជំទាស់ កថាខណ្ឌ ៦ (គូសបញ្ជាក់បន្ថែម)។

[៧៥] ដីកាសម្រេចពិចារណាឡើងវិញដែលត្រូវបានជំទាស់ កថាខណ្ឌ ៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ស.ច.ស នឹងមានយុត្តាធិការបំពេញកិច្ច នៅពេលដែលការចោទប្រកាន់លើអំពើណាមួយដែលបានរំលោភបំពានលើវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង មានលក្ខណៈគ្រប់គ្រាន់ឱ្យខ្លួន "មានហេតុផលជឿ" ថា បុគ្គលណាម្នាក់ "អាច" បានផ្តល់យោបល់លើអំពើដែលបានចោទប្រកាន់។ វាមានសារៈសំខាន់ត្រូវកត់សម្គាល់ថា ពាក្យ "អាច" បានបន្ទាបនូវលក្ខខណ្ឌនៃ "ហេតុផលជឿ"។ នៅពេលពិចារណាអំពីការជ្រៀតជ្រែកមួយដែលអាចកើតឡើង ស.ច.ស គ្រាន់តែចាំបាច់ត្រូវមាន "ហេតុផលជឿ" ថា អំពើមួយដែលបានហាមឃាត់នៅក្នុងវិធាន ៣៥(១)(ក)-(ឆ) "អាច" កើតឡើង។ លក្ខខណ្ឌទាបដូច្នេះ អាចមានលក្ខណៈផ្ទុយពីលក្ខខណ្ឌសាកល្បងនៃ "មូលដ្ឋានគ្រប់គ្រាន់" ដែលមានលក្ខណៈខ្ពស់ជាងបន្តិច និងលក្ខខណ្ឌ "ឱ្យហួសពីវិមតិសង្ស័យ" ដ៏សំខាន់ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវតែបំពេញ ដើម្បីរកឱ្យឃើញថាបុគ្គលណាម្នាក់រំលោភបំពានលើវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង។

៦. យើងបានពិនិត្យមើលភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដើម្បីគាំទ្រលើការចោទប្រកាន់អំពីលទ្ធភាពថា មានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។ នៅពេលយើងពិនិត្យមើលភស្តុតាងទាំងនេះ យើងយល់ឃើញថា អង្គហេតុដែលបានដាក់ដោយសមហេតុផលបាននាំឱ្យយើងពិចារណាថា អង្គហេតុដែលបានលើកឡើងខាងលើ និងហេតុការណ៍ជាបន្តបន្ទាប់ បង្កើតជាហេតុផលជឿថា សមាជិកនៃរាជរដ្ឋាភិបាលម្នាក់ ឬ ច្រើន អាចជ្រៀតជ្រែកដោយចេតនាពិតប្រាកដលើសាក្សីដែលអាចមកផ្តល់សក្ខីកម្មនៅចំពោះមុខ ស.ច.ស។ ការរកឃើញនេះនៅតែបង្ហាញឱ្យឃើញ ដោយមិនគិតថាតើសាក្សីដែលត្រូវបានកោះហៅ អាច ឬ មិនអាចមានហេតុផលច្រើនជាងមួយ ដើម្បីមិនមកផ្តល់សក្ខីកម្ម។ អង្គហេតុសំខាន់ជាងនេះមួយនោះគឺ យោបល់របស់លោកខៀវ កាញារិទ្ធ ដែលបានចេញផ្សាយនៅក្នុងកាសែត*ភ្នំពេញប៉ុស្តិ៍* ថា "ជំហររបស់រដ្ឋាភិបាល គឺគាត់មិនគួរផ្តល់សក្ខីកម្មនោះទេ" នៅពេលនិយាយយោងដល់មន្ត្រី ៦ នាក់[៧៦]។ បរិបទ ដែលសេចក្តីថ្លែងការណ៍នេះបានលើកឡើង បាននាំឱ្យមានការជឿយ៉ាងខ្លាំងថា

---

[៧៦] សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ មានចំណងជើងថា៖ 'Govt testimony could bias KRT: PM' ចុះផ្សាយថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩។

សេចក្តីថ្លែងការណ៍នេះអាចជាការជ្រៀតជ្រែក ឬ ផ្ទុះបញ្ហាំងអំពីកិច្ចប្រឹងប្រែងផ្សេងៗទៀតក្នុងការរារាំងការស្តាប់សក្ខីកម្មរបស់មន្ត្រីទាំង៦រូបនេះ។ កាលៈទេសៈដែលបានបង្កើត "ហេតុផលជឿ" រួមមាន (i) ការកោះហៅមន្ត្រីទាំង៦រូប, (ii) ជំហររបស់បុគ្គលទាំងឡាយដែលត្រូវបានកោះហៅ [redacted], (iii) យោបល់ដែលថ្លែងជាសាធារណៈថា បុគ្គលទាំងនេះ "មិនគួរផ្តល់សក្ខីកម្ម", (iv) ការខកខានរបស់មន្ត្រីទាំង ៦ រូប ក្នុងការធ្វើទំនាក់ទំនងជាមួយនឹង ស.ច.ស ដើម្បីរៀបចំពេលវេលាមកផ្តល់សក្ខីកម្ម, និង (v) ការខកខានជាបន្តបន្ទាប់របស់មន្ត្រីទាំង ៦ រូបនេះ ក្នុងការមកផ្តល់សក្ខីកម្ម។ យោបល់របស់ ខៀវ កាញ្ញារិទ្ធ ធ្វើឱ្យយើងជឿថា មានហេតុផលជឿថា គាត់ ឬ បុគ្គលដែលគាត់ផ្តល់យោបល់ ដោយជំនួសមុខឱ្យនោះ អាចប៉ុនប៉ងដោយចេតនាពិតប្រាកដនៅក្នុងការគំរាមកំហែង ឬ បំភិតបំភ័យមន្ត្រីទាំង៦ រូប ឬ បើមិនដូច្នោះទេ ជ្រៀតជ្រែកលើការសម្រេចចិត្តរបស់មន្ត្រីទាំង៦ រូបនេះ ទាក់ទងនឹងការអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឱ្យមកផ្តល់សក្ខីកម្ម។

៧. នៅពេលសន្និដ្ឋានបែបនេះ វាមានសារៈសំខាន់ដែលត្រូវកត់សម្គាល់ថា នេះមិនមែនជាការសម្រេចចុងក្រោយលើករណីថា តើអំពើដែលបានចោទប្រកាន់នោះបាន ឬ មិនបានកើតឡើងដែរឬទេនោះទេ។ ការសន្និដ្ឋានេះគឺគ្រាន់តែជាការរកឃើញថា មានមូលហេតុជឿថា ការជ្រៀតជ្រែកអាចកើតឡើង ហេតុដូច្នេះហើយ មានមូលដ្ឋានគ្រប់គ្រាន់ ដែលតម្រូវឱ្យចាត់វិធានការបន្ថែម ក្នុងនោះរួមមាន ការអនុវត្តវិធានការ ដូចមានចែងនៅក្នុងវិធាន ៣៥(២)(ខ) នៃវិធានផ្ទៃក្នុង។ យើងត្រូវកត់សម្គាល់ផងដែរថា មន្ត្រីទាំង៦ រូបនេះ បំពេញគុណសម្បត្តិជា "សក្សីសំខាន់" ដូចមានចែងនៅក្នុងវិធាន ៣៥(១)(ឃ) នៃវិធានផ្ទៃក្នុង។

៨. នៅក្នុងការសម្រេចអំពីការចោទប្រកាន់ថាមានការជ្រៀតជ្រែកនេះ យើងយល់ឃើញថា ចំណាត់ការដែលសមស្របជាងគេបង្អស់នោះ គឺត្រូវ "ដឹកនាំកិច្ចស៊ើបអង្កេតបន្ថែមទៀត ដើម្បីឱ្យដឹងថាតើមានមូលដ្ឋានគ្រប់គ្រាន់ សម្រាប់បំពេញកិច្ចដំណើរការនីតិវិធីដែរឬទេ" ដោយអនុលោមតាមវិធាន៣៥(២)(ខ) នៃវិធានផ្ទៃក្នុង។ ដើម្បីទទួលបាននូវសេចក្តីសម្រេចដែលមានមតិភាគច្រើនគាំទ្រឱ្យមានកិច្ចស៊ើបអង្កេតចាំបាច់មួយនោះ អង្គបុរេជំនុំជម្រះនឹងជួបប្រឈមនឹងបញ្ហាយុទ្ធសាស្ត្រ។ តាមយោបល់របស់យើង ចំណាត់ការដែលសមស្របជាងគេបង្អស់នោះ គឺអង្គបុរេជំនុំជម្រះគួរត្រូវបានដឹកនាំកិច្ចស៊ើបអង្កេតនោះ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

នេះគឺដោយសារតែ ក.ស.ច.ស ដែលជាអង្គភាពស៊ើបសួររបស់ អ.វ.ត.ក បានបដិសេធម្តងហើយម្តងទៀត មិនស៊ើបអង្កេតលើបញ្ហានេះ ហើយនៅក្នុងស្ថានភាពនេះ ក.ស.ច.ស ប្រហែលមិនមែនជាអង្គភាពសមស្របជាងគេបង្អស់ ដើម្បីដឹកនាំកិច្ចស៊ើបសង្កេតទៅលើការចោទប្រកាន់ថាមានការជ្រៀតជ្រែកនោះឡើយ។

៩. ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការអាចមានន័យថា ជាការមិនគោរពឯករាជ្យភាពរបស់តុលាការដោយសារតែភាពធ្ងន់ធ្ងរនៃការចោទប្រកាន់ឡើងទាំងនេះ និងភាពដើមដែលបណ្តាលឱ្យមានការចោទប្រកាន់ទាំងនេះកើតឡើងនោះ យើងកត់សម្គាល់ឃើញថា ប្រសិនបើកកិច្ចស៊ើបអង្កេតណាមួយទទួលបានការមិនសហការពីភាគីណាមួយ អង្គបុរេជំនុំជម្រះអាចអនុវត្តវិធាន៣៥(២)(គ) ធ្វើជាវិធានការចុងក្រោយ ដើម្បីដោះស្រាយ។ បទប្បញ្ញត្តិនេះចែងថា នៅពេលដែល ស.ច.ស. ឬអង្គជំនុំជម្រះ មានហេតុផលដើម្បីជឿថាបុគ្គលណាមួយអាចបានប្រព្រឹត្តនូវអំពើជ្រៀតជ្រែក ដូចបានរៀបរាប់នៅក្នុងវិធាន៣៥(១)នោះ ស.ច.ស ឬអង្គជំនុំជម្រះអាច "បញ្ជូនបញ្ហានេះ ទៅអាជ្ញាធរមានសមត្ថកិច្ចសមស្របរបស់ព្រះរាជាណាចក្រកម្ពុជា ឬ អង្គការសហប្រជាជាតិ"។

១០. មានកត្តាជាមូលដ្ឋានចំនួន២ ដែលជាមូលដ្ឋាននៃការសម្រេចរបស់យើងដែលថា ត្រូវបំពេញកិច្ចស៊ើបសួរបន្ថែម។ ទីមួយ អង្គជំនុំជម្រះមានកាតព្វកិច្ចធានារក្សានូវសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធី។ ដូចដែល អង្គជំនុំជម្រះបានកត់សម្គាល់ពីខាងដើមគឺថា៖

> "វិធាន៣៥ត្រូវបានបញ្ចូលទៅក្នុងវិធានផ្ទៃក្នុងជាយន្តការមួយ ដើម្បីរក្សាសុច្ចរិតភាពនៃដំណើរការតុលាការទាំងនៅដំណាក់កាលស៊ើបសួរនិងកាត់សេចក្តី។ សុច្ចរិតភាពនៃដំណើរការនេះគឺត្រូវបានធានាតាមរយៈការយកវិធាននេះមកអនុវត្ត នៅពេល ស.ច.ស ឬ អង្គជំនុំជម្រះណាមួយចាត់ទុកថាទង្វើរបស់ជនណាម្នាក់ ជាការគំរាមកំហែងដល់កិច្ចការតុលាការ"[៧៧]។

១១. ចៅក្រមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ត្រូវពិចារណាលើកាតព្វកិច្ចរបស់ខ្លួនក្នុងការបំពេញកិច្ច នៅពេលអំពើរបស់បុគ្គលណាម្នាក់ជាការគម្រាមកំហែងលើកិច្ចការរបស់តុលាការ។ គ្រប់ចៅក្រមនៃ អ.វ.ត.ក ទាំងអស់ ត្រូវគោរពតាមមាត្រា១ នៃក្រមសីលធម៌ចៅក្រម ដែលចែងថា "ចៅក្រមត្រូវរក្សានូវឯករាជ្យភាពនៃការិយាល័យរបស់ខ្លួន និងសិទ្ធិអំណាចរបស់ខ្លួននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា អ.វ.ត.ក) ហើយត្រូវប្រតិបត្តិតាមសិទ្ធិអំណាច និងឯករាជ្យភាព

[៧៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ក្នុងការបំពេញតួនាទីរបស់ខ្លួន”[៧៨]។ នៅពេលចៅក្រមជឿថា ព័ត៌មាននៅចំពោះមុខខ្លួន មានហេតុផលជឿថា ការជ្រៀតជ្រែកដូចបានកំណត់នៅក្នុងវិធានផ្ទៃក្នុងបានកើតឡើង ការអនុវត្តឆន្ទានុសិទ្ធិរបស់តុលាការមានការថយចុះ។ ចៅក្រមលែងមានឆន្ទានុសិទ្ធិទូលំទូលាយទៀតឡើយចំពោះវិធានការបន្ត ដែលត្រូវចាត់ការ។ ដូច្នេះ នៅក្នុងករណីនេះ ការអនុវត្តឆន្ទានុសិទ្ធិរបស់ចៅក្រម មិនដូចគ្នាទាំងស្រុងទៅនឹងឆន្ទានុសិទ្ធិ ដែលអនុវត្តដោយ ស.ច.ស និង ចៅក្រមនៃអង្គជំនុំជម្រះនេះឡើយ នៅពេលដែលខ្លួនជួបប្រឈមនឹងសំណើ ឬបណ្តឹងឧទ្ធរណ៍ប្រភេទផ្សេងៗ ដែលផ្អែកលើសំណើជាក់លាក់ ដូចជា សំណើធ្វើឡើងតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

១២. កត្តាទី២ដែលជាមូលដ្ឋាននៃទស្សនៈរបស់យើង គឺសិទ្ធិរបស់ជនត្រូវចោទម្នាក់ៗក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌។ ប្រសិនបើមានការជ្រៀតជ្រែកណាមួយឬកំពុងមានការជ្រៀតជ្រែក ហើយការជ្រៀតជ្រែកនោះបង្កការរាំងស្ទះដល់កិច្ចស៊ើបសួរ ជនត្រូវចោទម្នាក់ៗអាចត្រូវបានរារាំងនូវការទទួលបានផលប្រយោជន៍ ដែលអាចមានដែលអាចទទួលបានពីសក្ខីកម្មរបស់មន្ត្រីទាំង៦រូបនោះ។ ការរារាំងមិនឱ្យមានការផ្តល់សក្ខីកម្មពីសាក្សីដែលគេបានចាត់ទុកថា អាចនាំទៅរកការបង្ហាញការពិត អាចរំលោភលើយុត្តិធម៌នៃការកាត់សេចក្តី។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY កាលពីពេលថ្មីៗ បានគូសបញ្ជាក់ក្នុងបញ្ហា Prosecution v. Haradinaj et al., ថា “ក្នុងកាលៈទេសៈដែល មានការបំភិតបំភ័យសាក្សីដូចជាករណីនេះជាដើម វាជាការចាំបាច់ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវប្រឹងឱ្យអស់លទ្ធភាពដើម្បីធានាឱ្យមាននូវការកាត់សេចក្តីមួយ ដែលប្រកបទៅដោយយុត្តិធម៌”[៧៩]។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នេះបានបន្តថា ការតបតទៅនឹងការបំភិតបំភ័យសាក្សី “គឺជារឿងបន្ទាន់ នៅពេលកម្លាំងខាងក្រៅព្យាយាមបំផ្លាញលទ្ធភាពរបស់ភាគីក្នុងការបង្ហាញភស្តុតាងនៅសវនាការ។ ដើម្បីឱ្យតុលាការនេះដើរតួនាទីប្រកបដោយប្រសិទ្ធភាព អង្គជំនុំជម្រះសាលាដំបូងត្រូវតបតនឹងការបំភិតបំភ័យ សាក្សីដោយ

---

[៧៨] ក្រមសីលធម៌ចៅក្រម ដែលត្រូវបានអនុម័តនៅកិច្ចប្រជុំពេញអង្គរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងត្រូវបានធ្វើវិសោធកម្មនៅ កិច្ចប្រជុំពេញអង្គរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា១(១)។

[៧៩] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ramush Haradinaj និងជនដទៃទៀត* IT-04-84-A “សាលដីកា” អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌ៣៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ចាត់វិធានការចាំបាច់ដែលមាន..."[៨០]។ យើងក៏មានទស្សនៈយល់ឃើញដូចអង្គបុរេជំនុំជម្រះតុលាការឧទ្ធរណ៍ដែរ។ ប្រការសំខាន់ ទស្សនៈទាំងអស់នេះត្រូវបានសំដែងដោយអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ពាក់ព័ន្ធនឹងសាក្សីចោទប្រកាន់ ដែលអាចពង្រឹងភាពពាក់ព័ន្ធរបស់ពួកគេ ទៅនឹងបញ្ហានៅចំពោះមុខយើង។ ជាការចាំបាច់ ដែលអង្គជំនុំជម្រះត្រូវ *ប្រឹងឲ្យអស់លទ្ធភាព* ដើម្បីធានាថា ជនជាប់ចោទម្នាក់ៗ ទទួលបានការកាត់សេចក្តីដោយយុត្តិធម៌។

**ភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០** ✓

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

**ចៅក្រម** Rowan DOWNING **ចៅក្រម** Catherine MARCHI-UHEL

---

[៨០] ដូចដើងទំព័រខាងលើ។

# មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន៉យ ឋុល និង ចៅក្រម ហួត វុទ្ធី

១. ដូចដែលបានពិចារណារួចហើយថា ការបកស្រាយលើវិធាន៣៥របស់ ស.ច.ស ជាការភ័ន្តច្រឡំ ហើយសហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានសម្រេច យោងតាមអំណាចសាលដីកាសម្ងាត់របស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍របស់ លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី០៨ ខែមិថុនាឆ្នាំ២០១០ ("សាលដីកាលើសំណើសុំឱ្យកោះហៅសាក្សី")ថា៖ "បង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាឡើងវិញលើសំណើទាំងនេះ ទៅតាមការបកស្រាយត្រឹមត្រូវ លើវិធាន៣៥នៃវិធានផ្ទៃក្នុងដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៣២ ដល់ កថាខណ្ឌ ៤៥"[៨១]។

២. អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យ ស.ច.ស "ពិចារណាឡើងវិញថា តើគួរ ឬមិនគួរបើកការស៊ើបសួរ ដោយការពិចារណាលើការបកស្រាយ[វិធាន ៣៥ នៃវិធានផ្ទៃក្នុង]ដោយត្រឹមត្រូវ ដូចដែលបានគូសបញ្ជាក់ខាងលើ លើមតិយោបល់របស់បុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងសំណើ និងបុគ្គលទាំងឡាយ ដែលស្ថិតនៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា ដែលមតិយោបល់ទាំងនេះ អាចមានផលប៉ះពាល់ដល់លទ្ធភាព ឬឆន្ទៈរបស់សាក្សី ដែលត្រូវបានកោះហៅឱ្យមកចូលរួមផ្ដល់សក្ខីកម្មដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ"[៨២]។ ចំណុចសំខាន់នោះ គឺអង្គបុរេជំនុំជម្រះសូមគូសបញ្ជាក់ថា សេចក្ដីបង្គាប់របស់ ខ្លួនធ្វើឡើង

---

[៨១] សាលដីកាសម្ងាត់លើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោកនួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស. ច.ស លើសំណើសុំកោះហៅសាក្សី" ("សាលដីកាលើសំណើសុំកោះហៅសាក្សី") ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D314/1/8 ទំព័រ ២៨។

[៨២] សូមមើល"ដីកាកោះសាក្សី [redacted]

ដោយយោងតាមការបកស្រាយដោយត្រឹមត្រូវលើវិធាន៣៥នៃវិធានផ្ទៃក្នុង ហើយសេចក្តីបង្គាប់នេះ មិនមែនជាការណែនាំដល់ ស.ច.ស អំពីរបៀបបំពេញកិច្ចរបស់ខ្លួនឡើយ"[៨៣]។

៣. ឆ្លើយតបនឹងសាលដីកាលើសំណើសុំឱ្យកោះហៅសាក្សី ស.ច.ស បានរកឃើញដោយឯកច្ឆន្ទ នៅក្នុងដីកាឆ្លើយតប ចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើសុំកោះហៅសាក្សី" ("ដីកាសម្រេចលើកទីពីរ") ដូចខាងក្រោម៖

> ១. សហចៅក្រមស៊ើបអង្កេតបានធ្វើការពិនិត្យឡើងវិញលើសំណើសុំ ដោយពិចារណាលើការបកស្រាយរបស់អង្គបុរេជំនុំជម្រះចំពោះវិធាន ៣៥(១)(ឃ) នៃវិធានផ្ទៃក្នុង ជាពិសេសដើម្បីពិនិត្យអំពីអត្ថិភាពជា យថាហេតុនៃទំនាក់ទំនងរវាងសេចក្តីថ្លែងការណ៍របស់សមាជិកខ្លះនៃរាជរដ្ឋាភិបាល និងការសម្រេចចិត្ត របស់សាក្សីក្នុងការមិនមកបង្ហាញខ្លួន។
>
> ២. ចំពោះខ្លឹមសារ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា អ្វីដែលថ្មីដែលមិនមាននៅក្នុងដីកាសម្រេចកាលពីពេលមុន [redacted]"[៨៤]។

៤. ការណ៍ដែលសហចៅក្រមស៊ើបអង្កេតសម្រេចយ៉ាងនេះ ដោយសំអាងហេតុថា "...*ការចោទប្រកាន់ទាំងអស់ ដែលមានក្នុងសំណើសុំ មិនមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការផ្តល់យុត្តិកម្ម ចំពោះការអនុវត្តបញ្ញត្តិនៃវិធាន៣៥នៃវិធានផ្ទៃក្នុង នៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះឡើយ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនឱ្យមានការបើកកិច្ចស៊ើបសួរបន្ថែមលើអង្គហេតុទាំងនេះ...* "[៨៥]។

---

[៨៣] សាលដីកាលើសំណើសុំកោះហៅសាក្សី កថាខណ្ឌទី៥៤។

[៨៤] ដីកាឆ្លើយតបចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើសុំកោះហៅសាក្សី"ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D314/3 ("ដីកាសម្រេចលើកទីពីរ") កថាខណ្ឌទី ៤-៥។

[៨៥] ដីកាសម្រេចលើកទីពីរ") កថាខណ្ឌទី៦ (គូសបញ្ជាក់បន្ថែម)។

៥. ដើម្បីពិចារណាថា តើសហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេច មិនបង្គាប់ឱ្យមានការបំពេញកិច្ចស៊ើបសួរបន្ថែម ដូចមានចែងនៅក្នុងកថាខណ្ឌ ៤ខាងលើ មិនមានកំហុស ដូចដែលបានចោទប្រកាន់ដោយមេធាវីការពារក្តីរបស់ជនត្រូវចោទ នួន ជា និង អៀង សារី ឡើយ វាជាការសមស្របក្នុងការពិចារណាលើការចោទប្រកាន់ទាំងអស់ ដែលបានលើកឡើងដោយ មេធាវីការពារក្តី [នួន ជា] និង[អៀង សារី]។

៦. ការចោទប្រកាន់ថា “...ឯកឧត្តម ខៀវ កាញារិទ្ធ ជាអ្នកនាំពាក្យរាជរដ្ឋាភិបាល បាននិយាយជាសាធារណៈថា “បើទោះជា [មន្ត្រីជាន់ខ្ពស់ទាំង៦រូប] អាចចូលខ្លួនទៅតុលាការដោយខ្លួនឯងក៏ដោយ តែជំហររបស់រដ្ឋាភិបាល គឺគាត់មិនគួរផ្តល់សក្ខីកម្មនោះទេ ...បុគ្គលិកបរទេសអាចវេចសម្លៀកបំពាក់ ហើយត្រឡប់ទៅផ្ទះវិញ” ប្រសិនបើខ្លួនមិនពេញចិត្តនឹងសេចក្តីសម្រេចនេះ”[៨៦] ដែលបានលើកឡើងនៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ សហមេធាវីការពារក្តីរបស់លោក នួន ជា បានចាត់ទុកថា ជាការចោទប្រកាន់អំពីការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលតុលាការ។

៧. ចំពោះការចោទប្រកាន់នេះ យើងយល់ឃើញថា សំដីរបស់ឯកឧត្តម ខៀវ កាញារិទ្ធ មិនអាច រារាំង ឬហាមឃាត់ ឬគំរាមកំហែង ដោយផ្ទាល់ ឬដោយប្រយោលដល់សាក្សី [មន្ត្រីជាន់ខ្ពស់] ទាំង៦រូប មិនឱ្យចូលខ្លួនទៅតុលាការទេ គឺគាត់ទទួលស្គាល់ថា “សាក្សី [មន្ត្រីជាន់ខ្ពស់] អាចចូលខ្លួនដោយខ្លួនឯង”[៨៧]។ អ្នកនាំពាក្យរូបនេះបានបន្តទៀតថា កាលបើចូលខ្លួនហើយ “ជំហររបស់រដ្ឋាភិបាល គឺថាគាត់មិនគួរផ្តល់សក្ខីកម្មនោះទេ”[៨៨]។

---

[៨៦] សំណើសុំបំពេញកិច្ចស៊ើបសួររបស់លោក នួន ជា ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D254 កថាខណ្ឌទី៧។

[៨៧] “សក្ខីកម្មរបស់រដ្ឋាភិបាលអាចមានលម្អៀងដល់សាលាក្តីខ្មែរក្រហម៖ នាយករដ្ឋមន្ត្រី” កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០០៩។

[៨៨] សក្ខីកម្មរបស់រដ្ឋាភិបាលអាចមានលម្អៀងដល់សាលាក្តីខ្មែរក្រហម៖ នាយករដ្ឋមន្ត្រី” កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០០៩។

សំដីទាំងនេះ ពុំមានលក្ខណៈគំរាមកំហែង បំភិតបំភ័យ ឬបង្ខំដោយផ្ទាល់ ឬដោយប្រយោលលើករណីបុគ្គល[មន្ត្រីជាន់ខ្ពស់] ទាំងនោះទេ ពីព្រោះឯកឧត្តម ខៀវ កាញារីទ្ធ បានប្រើពាក្យ "មិនគួរ" មិនមែនប្រើពាក្យ "មិនត្រូវ" ដែលមានលក្ខណៈជាបញ្ជាដាច់ខាតនោះទេ ហើយគាត់មិនបានអះអាងថា គាត់និយាយក្នុងនាមរដ្ឋាភិបាលនោះដែរ។

៨. យើងក៏កត់សម្គាល់ឃើញផងដែរថា ទោះបីជាសេចក្តីថ្លែងការណ៍ ឬសុន្ទរកថារបស់អ្នកតំណាងរដ្ឋាភិបាល ដែលបានលើកឡើងប្រាប់អ្នកសារព័ត៌មាន និងនៅក្នុងកាសែត ត្រូវចាត់ទុកជាកំណត់ហេតុពិតប្រាកដក៏ដោយ ក៏យើងមិនយល់ឃើញថា សេចក្តីថ្លែងការណ៍ ឬសុន្ទរកថានេះ មានតម្លៃជាភស្តុតាងដែលអាចជឿជាក់បាន និងគ្រប់គ្រាន់ ដែលអាចឱ្យយើងមានហេតុផលជឿថា បុគ្គលម្នាក់អាចប្រព្រឹត្តអំពើដូចមានចែងនៅក្នុងវិធាន៣៥(១) នៃវិធានផ្ទៃក្នុងទេ។

៩. បើពិចារណាទៅលើឋានៈតួនាទី ឬឋានន្តរសក្តិវិញ ឯកឧត្តម ខៀវ កាញារីទ្ធ មានឋានៈត្រឹមតែជារដ្ឋមន្ត្រី និងអ្នកនាំពាក្យតែប៉ុណ្ណោះ ឯសាក្សីទាំង៦រូបវិញ ជាឥស្សរជនជាន់ខ្ពស់មានឋានៈខ្ពស់ជាង ចាប់ពីឋានៈឧបនាយករដ្ឋមន្ត្រី។ ដូច្នេះ ជាគោលការណ៍ មន្ត្រីដែលមានឋានៈទាប ឧទាហរណ៍ដូចឯកឧត្តម ខៀវ កាញារីទ្ធ ពុំអាចបង្គាប់បញ្ជា ឬ បង្ខំឱ្យមន្ត្រីឋានៈខ្ពស់ជាងខ្លួន[តាមឋានានុក្រមក្នុងជួររដ្ឋមន្ត្រី] ឱ្យអនុវត្តតាមបង្គាប់របស់ខ្លួនឡើយ។ ហើយបើទោះបីជា ឯកឧត្តម ខៀវ កាញារីទ្ធ ជាអ្នកនាំពាក្យរាជរដ្ឋាភិបាលបាននិយាយក៏ដោយ ក៏ពុំមានឯកសារជាលាយលក្ខណ៍អក្សរណាមួយ ដែលជាតំរុយអាចបញ្ជាក់បានថា សាក្សី[មន្ត្រីជាន់ខ្ពស់]ទាំង៦រូបនោះ មិនចូលខ្លួនផ្តល់សក្ខីកម្ម ដោយសារតែពួកគាត់ភ័យខ្លាច ចំពោះការនិយាយថ្លែង ដោយអ្នកនាំពាក្យរាជរដ្ឋាភិបាលនោះដែរ។

១០. យើងតម្កល់ដីកាសម្រេចលើកទីពីរ និងយកសំអាងហេតុរបស់យើងនៅក្នុងកថាខណ្ឌទី ៧ ៨ និង៩ខាងលើ មកជំនួសសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត ដោយយល់ឃើញថា ដីកាសម្រេចលើកទីពីរឆ្លុះបញ្ចាំងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងត្រឹមត្រូវ ក្នុងការសម្រេចមិនបង្គាប់ឱ្យមានការបំពេញកិច្ចស៊ើបសួរបន្ថែម។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ<u>៥០</u> និង ៥១)

លេខ/No. D314/1/12

១១. ដូច្នេះ យើងចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហ្វួត វុទ្ធី តម្កល់ដីកាសម្រេចលើកទី២ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០។

**ភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០**

ចៅក្រម **ប្រាក់ គីមសាន** ចៅក្រម **ន័យ ថុល** ចៅក្រម **ហ្វួត វុទ្ធី**